# ព្រះរាជក្រឹត្យ

នស / រកត /០៦០២/ ១៥៤

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៣៩៩ / ៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :-**

ត្រូវបានបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីបំពេញបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ លើវិស័យច្បាប់ និងយុត្តិធម៌ ហើយដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | ឌិត | មុន្ទី | ប្រធានតុលាការកំពូល | ជាសហប្រធាន |
| ២-ឯកឧត្តម | សុខ | អាន | ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ៣-ឯកឧត្តម | នាវ | ស៊ីថុង | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៤-លោកជំទាវ | លី | វួចឡេង | ប្រធានសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| ៥-ឯកឧត្តម | ហេង | ចន្ទ្រមុនីនារត | អនុប្រធានក្រុមប្រឹក្សាមេធាវី | ជាសមាជិក |
| ៦-ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

៧.ឯកឧត្តម សុខ ស៊ីផាន់ណា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក

៨.ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ២ ៈ-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានទីតាំងស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៣ ៈ-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានបេសកកម្ម ផ្តួចផ្តើម ជំរុញ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តនយោបាយ និងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៤ ៈ-**

ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥ ៈ-**

សមាជិកនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៦ ៈ-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវមានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍មួយ ជាអ្នកសំរបសំរួលដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា ជាមួយស្ថាប័នរដ្ឋ និងស្ថាប័នអន្តរជាតិនានា ដែលពាក់ព័ន្ធ ។

**មាត្រា ៧ ៈ-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៨ ៈ-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង. រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២*

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣/រ-០៤-០៦-០០១៦៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជាសូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ១៤៤ ច.ល

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០០២

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**